ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាព
# គណៈកម្មការចំពោះកិច្ចចុះបញ្ជីដី
# តំបន់ទន្លេសាប

២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៩ សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអធិការកិច្ច
- បានឃើញសេចក្ដីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# **សម្រេច**

**ប្រការ ១.** _

តែងតាំងសមាសភាពគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សាយ សំអាល់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម **ថោ ជេដ្ឋា** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣- | ឯកឧត្តម **ឌិត ទីណា** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- | ឯកឧត្តម **អ៊ាង សុផល្លែត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៥- | ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦- | ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តកំពង់ឆ្នាំង | សមាជិក |
| ៧- | ឯកឧត្តម **កែវ រតនៈ** | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងជាប្រធាន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តពោធិ៍សាត់ | សមាជិក |
| ៨- | ឯកឧត្តម **សម្បត្តិ ហ៊ុំណា** | អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ៩- | ឯកឧត្តម **ឈឹន សុភាព** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- | ឯកឧត្តម **ស៊ឹម ស៊ីយុន** | រដ្ឋលេខាធិការក្រសួងអធិការកិច្ច | សមាជិក |
| ១១- | ឯកឧត្តម **ខាន់ វណ្ណៈ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាសមាជិក ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបាត់ដំបង | សមាជិក |
| ១២- | ឯកឧត្តម **គង់ ច័ន្ទវាសនា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជា សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀត នរិន្ទ** | រដ្ឋលេខាធិការក្រសួងការពារជាតិ និងជា សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តសៀមរាប | សមាជិក |
| ១៤- | ឯកឧត្តម **ឡៅ ដារិទ្ធ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិកអចិន្ត្រៃយ៍ |
| ១៥- | ឯកឧត្តម **ហ៊ីង បញ្ញាវុឌ្ឍ** | អនុរដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៦- | ឯកឧត្តម **ឡៅ ម៉ុងលីវេត** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី និងជា សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ | សមាជិក |
| ១៧- | ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពល ខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩- | ឧត្តមសេនីយ៍ទោ **ឈឹម សុវិសាល** | នាយសេនាធិការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាតំណាងគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ | សមាជិក |
| ២០- | ឯកឧត្តម **ស៊ុន សុវណ្ណារិទ្ធិ** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |

| | | |
|---|---|---|
| ២១- ឯកឧត្តម **ខូយ រីដា** | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ២២- ឯកឧត្តម **សុខ លូ** | អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ២៣- ឯកឧត្តម **អ៊ុំ រាត្រី** | អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ២៤- ឯកឧត្តម **ឃ្លាក់ សោភណ្ឌ** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ២៥- ឯកឧត្តម **ខួន រតនៈ** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |

**ប្រការ ២.-**

តួនាទី និងភារកិច្ចរបស់គណៈកម្មការចំពោះកិច្ចនេះ មានចែងក្នុងសេចក្ដីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអធិការកិច្ច ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍១៣ កើតខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តជុំវិញតំបន់ទន្លេសាប
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ